សេចក្តីប្រកាសពត៌មាន

# ភាគីបានចុះហត្ថលេខា នៅលើអនុស្សរណៈនៃការយោគយល់គ្នា ដើម្បីបន្តប្រតិបត្តិការ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារ

ថ្ងៃព្រហស្បត្តិ៍ ទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩

---

**ភ្នំពេញ ប្រទេសកម្ពុជា៖** អនុស្សរណៈយោគយល់គ្នា នឹងឆ្លុះបញ្ចាំងពីភាពជាដៃគូររវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ) សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារសម្រាប់រយៈពេល៣ឆ្នាំខាងមុខទៀត គិតចាប់ពីខែ មករា ឆ្នាំ២០២០ ដល់ខែធ្នូ ២០២២ ដែលក្នុងកំឡុងនេះ ដៃគូរបានប្តេជ្ញាចិត្ត ដើម្បីកែលម្អលក្ខខណ្ឌការងារ នៅក្នុងវិស័យវាយនភ័ណ្ឌ និងកាត់ដេរសម្លៀកបំពាក់ ព្រមទាំងពង្រីកវិសាលភាព នៃការអនុវត្តអនុស្សរណៈយោគយល់គ្នានេះ ដោយដាក់បញ្ចូលវិស័យផលិតផលធ្វើដំណើរ និងកាបូបនៅប្រទេសកម្ពុជាផងដែរ។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារ នឹងបន្តវិសាលភាពរបស់ខ្លួនមិនត្រឹមតែវិស័យកាត់ដេរសំលៀកបំពាក់ តែរួមទាំងវិស័យផលិតផលធ្វើដំណើរ និងកាបូបនៅប្រទេសកម្ពុជាផងដែរ។ ចាប់តាំងពីឆ្នាំ ២០០១មក រាជរដ្ឋាភិបាលកម្ពុជា បានផ្សារភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មទៅនឹងស្តង់ដារការងារនៅក្នុងឧស្សាហកម្មកាត់ដេរ នភណ្ឌនៅកម្ពុជា វាយដើម្បីលើកកម្ពស់ ការអនុលោម និងអនុវត្តច្បាប់ការងារដែលមានស្រាប់ ដោយយោងទៅតាមក្រមច្បាប់ស្តីពីការងារដែលទទួលស្គាល់ជាអន្តរជាតិ។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នឹងបន្តធ្វើការវាយតម្លៃស្តីពីលក្ខខណ្ឌការងារ នៅក្នុងរោងចក្រកាត់ដេរដោយផ្អែកទៅតាមច្បាប់ស្តីពីការងារ របស់ប្រទេសកម្ពុជា និងបទដ្ឋានស្នូលការងារ ដែលទទួលស្គាល់ជាអន្តរជាតិ។ សេវាកម្មប្រឹក្សាយោបល់ និងវគ្គបណ្តុះបណ្តាលនានា ស្តីពីការធ្វើឲ្យកន្លែងការងារ មានប្រសើរឡើង ព្រមទាំងបង្កើនផលិតភាព នឹងបន្តប្រតិបត្តិការជាទៀងទាត់ ជាមួយនឹងការយកកម្រៃសេវាទាំងនេះ។ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ក៏នឹងបន្តធ្វើការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្ត និងសកម្មភាពរួមគ្នា ដោយគោលបំណងជួយបង្កើនសមត្ថភាពក្រសួងសម្រាប់ការធ្វើអធិការកិច្ច និងភាពជាម្ចាស់ការ ដើម្បីលើកកម្ពស់ការអនុលោមច្បាប់ស្តីការងារ និងគាំទ្រក្នុងការដោះស្រាយនៅក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង វិស័យផលិតផលធ្វើដំណើរ និងកាបូបនៅប្រទេសកម្ពុជា។ លើសពីនេះ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នឹងបន្តធ្វើការជាមួយសមាគម

រោងចក្រកាត់ដេរ និងអ្នកផលិតវិស័យផលិតផលធ្វើដំណើរ និងកាបូប ដើម្បីធ្វើការរួមគ្នា ក្នុងការបង្កើនសមត្ថភាពរបស់រោងចក្រ សម្រាប់ការអនុលោមច្បាប់ ប្រកបដោយចីរភាព និងគាំទ្រដល់ពួកគេ ក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រង ។

**ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានមានប្រសាសន៍ថា “តាមរយៈការអនុវត្តគោលនយោបាយនៃការផ្សារភ្ជាប់ពាណិជ្ជកម្ម ជាមួយនឹងបទដ្ឋានការងារ បានប្រែក្លាយកេរ្តិ៍ឈ្មោះរបស់កម្ពុជាទៅជាប្រទេសឈានមុខគេក្នុងគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ និងបានធ្វើអោយកម្ពុជា ក្លាយជាប្រទេសគំរូសម្រាប់ប្រទេសមួយចំនួនយកទៅធ្វើជាបទពិសោធន៍ សម្រាប់យកទៅអនុវត្ត និងរៀនសូត្រតាម។ ការអនុវត្តគោលនយោបាយនៃការផ្សារភ្ជាប់ពាណិជ្ជកម្ម ជាមួយនឹងបទដ្ឋានការងារ ក៏បានបង្កើនទំនុកចិត្តដល់អ្នកបញ្ជាទិញម៉ាកយីហោល្បីៗក្នុងការដាក់បន្ថែមការបញ្ជាទិញផលិតផល សម្លៀកបំពាក់ និងវាយនភ័ណ្ឌនៅកម្ពុជា” ។

ជាមួយគ្នានេះដែរ **ឯកឧត្តម បណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា “តាមរយៈគោលនយោបាយ នៃការភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្ម ជាមួយបទដ្ឋានការងារ ប្រទេសកម្ពុជាកំពុងទទួលបានកេរ្តិ៍ឈ្មោះល្អ ហើយក្លាយជាប្រទេសឈានមុខគេ នៅក្នុងគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ ព្រមទាំង កំពុងដើរតួនាទីជាគំរូ សម្រាប់ប្រទេសមួយចំនួន។ ការអនុវត្តគោលនយោបាយនេះ គឺក៏ដើម្បីជួយឲ្យអ្នកទិញ ឲ្យទទួលបានប្រភពបញ្ជាទិញសម្លៀកបំពាក់ ដែលគួរអោយទុកចិត្តបាននៅប្រទេសកម្ពុជា” ។

**លោក វ៉ាន់ សូអៀង** ប្រធានសមាគមរោងចក្រកាត់ដេរ បានលើកឡើងថា “សមាគមរោងចក្រកាត់ដេរ នឹងបន្តធ្វើការជាមួយរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរក្សាការផលិតសុវត្ថិភាពការងារ និងការងារប្រកបដោយចីរភាព សម្រាប់ជាកម្លាំងពលកម្មរបស់កម្ពុជារបស់យើង” ។

ចំណែកឯលោក **Graeme Buckley** នាយកអង្គការអន្តជាតិខាងការងារ ប្រចាំប្រទេសថៃ កម្ពុជា និងឡាវ បានកត់សម្គាល់ថា “ដោយធ្វើការជាមួយរាជរដ្ឋាភិបាល និងសមាគមរោងចក្រកាត់ដេរ យើងនឹងរួមគ្នាលើកកម្ពស់ការងារសមរម្យសម្រាប់កម្មកររាប់រយ រាប់ពាន់នាក់ ជាពិសេសស្ត្រី ហើយក៏ជួយកម្មករនិយោជិតក្នុងការអភិវឌ្ឍជំនាញថ្មីៗអាជីវកម្ម ដើម្បីទទួលប្រាក់ចំណេញកាន់តែច្រើនជាងមុន និងក្រុមគ្រួសារពួកគេឲ្យចាកផុតពីភាពក្រីក្រ” ។

អនុស្សរណៈយោគយល់គ្នានេះ ត្រូវបានបន្តសារជាថ្មី ជាលើកទី៦ ចាប់តាំងពីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារ ចាប់ផ្តើមមានវត្តមានរបស់ខ្លួន តាំងពីឆ្នាំ២០០១មក។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា គឺជាផ្នែកមួយនៃកម្មវិធីការងារកាន់តែប្រសើរជាងមុន ដែលសហការរវាងអង្គការអន្តរជាតិខាងការងារ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលកំពុងប្រតិបត្តិការនៅទ្វីបចំនួន ៣ ដើម្បីផ្លាស់ប្តូរនៅតាមខ្សែចង្វាក់ផ្គត់ផ្គង់ជាសកល នៅក្នុងឧស្សាហកម្មកាត់ដេរ ការងាររបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាក្លាយជាផ្នែកមួយដ៏សំខាន់ នៅក្នុងកម្មវិធីការងារសមរម្យនៅប្រទេសកម្ពុជា ដែលបានចុះហត្ថលេខា នេះ។

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោកស្រី សារ៉ា ផាក**

ប្រធានគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តជាតិខាងការងារ

អ៊ីម៉ែល៖ park@ilo.org